មជ្ឈមណ្ឌលឯកសារកម្ពុជា

# អង្គជំនុំជម្រះសាលាដំបូងព្រមានអកប្បកិរិយាក្រអឺតក្រទម របស់មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន

**ចាន់ ប្រាថ្នា**

**ពិនិត្យដោយៈ ឆាំង យុ**

នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញសេចក្តីព្រមានដល់លោក អាថឺ វែរកិន ជាសហមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន។ សេចក្តីព្រមាននេះធ្វើឡើងបន្ទាប់ពីមេធាវី អាថឺ វែរកិន បានស្រែកទាំងកំហឹងនៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ុំ អាឡាត់ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣។ បន្ថែមលើនេះទៀត បន្ទាប់ពីអង្គជំនុំជម្រះប្រកាសបិទសវនាការ និងធ្វើដំណើរចាកចេញពីបន្ទប់សវនាការ មេធាវី អាថឺ វែរកិន នៅតែបន្តអង្គុយដោយពុំព្រមក្រោកឈរនៅខណៈពេលដែលភាគីផ្សេងៗទៀត និងសារធារណជនទូទៅនៅក្នុងបន្ទប់នោះឡើងក្រោកឈរទាំងអស់គ្នា។ គួរបញ្ជាក់ថា តាមការអនុវត្តកន្លងមក រាល់ពេលចៅក្រមនៃអង្គជំនុំជម្រះធ្វើដំណើរចូល និងចេញពីបន្ទប់សវនាការ គ្រប់បុគ្គលទាំងអស់នៅក្នុងបន្ទប់សវនាការ (លើកលែងតែព្រះសង្ឃ) ត្រូវក្រោកឈរ។ ការអនុវត្តនេះ គឺអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់តុលាការដែលចែងថា សាធារណជន និងភាគីទាំងអស់ត្រូវក្រោកឈរនៅពេលដែលក្រឡាបញ្ជីបញ្ជាក់ថា«ក្រោកឈរ»។[១]

តាមរយៈសកម្មភាពទាំងនេះ អង្គជំនុំជម្រះធ្វើការកត់សម្គាល់ជាសាធារណៈថា មេធាវី អាថឺ វែរកិន មានអកប្បកិរិយាក្រអើតក្រទម និងមានចរិតរំខានដល់កិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខភាគីផ្សេងៗទៀតដែលជាសហសេវិករួមវិជ្ជាជីវៈជាមួយគ្នា សាក្សី និងសាធារណជន។ វិធាន ២២(៤) នៃវិធានផ្ទៃក្នុងចែងថា «នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និង បទដ្ឋាននិងក្រមសីលធម៌វិជ្ជាជីវៈដែលបានទទួលស្គាល់។ ពួកគេមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធិភាព និងត្រឹមត្រូវ»។[២]

---

១-បទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការក្នុងថ្ងៃសវនាការ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១។

២-វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជា(វិសោធនកម្មលើកទី៨) ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១។

ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣

អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមថា អកប្បកិរិយារបស់មេធាវី អាថឺ វែរកិន គឺធ្លាក់ចុះក្រោមបទដ្ឋានគំរូនៃការគោរពវិជ្ជាជីវៈដែលមេធាវីនានាត្រូវប្រកាន់យកនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ឬតុលាការផ្សេងៗទៀត។ ជាងនេះទៅទៀត អកប្បកិរិយាបែបនេះ គឺជាឧទាហរណ៍មិនល្អមួយសម្រាប់បណ្ដាមេធាវីជំនាន់ក្រោយផ្សេងៗទៀត។ ទោះបីមានការកត់សម្គាល់ដូច្នេះក្ដី អង្គជំនុំជម្រះពុំបានសម្រេចចាត់វិធានការណាមួយប្រឆាំងនឹងមេធាវី អាថឺ វែរកិន ឡើយ គឺគ្រាន់តែចេញសេចក្ដីព្រមានអនុលោមតាមវិធាន ៣៧(១) តែប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងករណីមេធាវីរូបនេះនៅតែបន្តអនុវត្តដូច្នេះ នោះអាចប្រឈមនឹងការបណ្ដេញចេញពីបន្ទប់សវនាការជាដើម។ វិធាន ៣៧(១) នៃវិធានផ្ទៃក្នុងចែងថា "*នៅពេលណាដែលអង្គជំនុំជម្រះយល់ឃើញថា ជនណាម្នាក់អុកឡុករំខានដល់កិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះជាដំបូងត្រូវចេញសេចក្ដីព្រមានមួយ ។ ក្នុងករណីមានការបន្តរំខានទៀត អង្គជំនុំជម្រះអាចបង្គាប់ឲ្យជនដែលរំខាននោះចាកចេញ ឬបណ្ដេញចេញពីបន្ទប់សវនាការ ឬអគាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយក្នុងករណីនៅតែប្រព្រឹត្តកំហុសឆ្គងទៀត អាចបង្គាប់មិនឲ្យជននោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់*" ។

ចប់